## ការជួយកូនរបស់អ្នកបើកប្រើលេខ គណនី ថ្មីសម្រាប់ Canvas  (Learning Management System)

Canvas គឺជាប្រព័ន្ធថ្មីនៃក្រសួងអប់រំ ឌីស្ទ្រីគ ឡុងប៊ីច សម្រាប់ប្រើចាត់ចែងជាជំនួយមកលើការរៀន និង ការបង្ហាត់តាមរយៈ អនឡាញ ។ ក្រសួងអប់រំ LBUSD បានបង្កើតជាលេខ គណនី Canvas សម្រាប់ផ្តល់ទៅកាន់សិស្សរៀនក្នុងក្រសួងអប់រំ ឌីស្ទ្រីគ ។ ជំហានទីមួយ គឺលែលកជួយសិស្សអោយមានជាលេខ គណនី ។ មាតាបិតាអាចជួយសិស្សរបស់ពួកគាត់បង្កើតជាលេខ គណនី ថ្មីបាន បន្ទាប់ម៉ោង 5 ល្ងាច នៅថ្ងៃនេះ ដោយធ្វើតាម**ក្បួនណែនាំដូចតទៅ** ។

ក្នុងរយៈពេលថ្ងៃជាបន្តបន្ទាប់ទៅ គឺមាតាបិតានឹងអាចរៀនចំណាំបានអំពីលេខ គណនី នៃសិស្សរបស់ពួកគាត់ ។ បន្ថែមពត៍មានសម្រាប់មាតាបិតាស្តីអំពី Canvas គឺមានផ្តល់ជូននៅតាមគេហទំព័រ **Canvas Parent Guide** ។

បើសិនជាបន្ទាប់ពីបានអានក្បួនណែនាំ និង បានចាក់មើលនៅតាម វិដេអូ ផុតទៅ ហើយអ្នកនៅតែមានបញ្ហាដដែលសម្រាប់ជួយកូនរបស់អ្នកអំពីរបៀបបង្កើតជាលេខ គណនី គឺជំនួយនឹងមានផ្តល់ជូនពីម៉ោង 5 ទៅ 8 យប់ នៅល្ងាចនេះ និង ចាប់ផ្តើម ម៉ោង 6:30 ព្រឹក នៅថ្ងៃអង្គារ រហូតដល់ពេលថ្ងៃសាលារៀនផ្តើម ដោយធ្វើការទាក់ទងតាមលេខ (562) 997-8324 ។ បើមានបញ្ហាផ្សេងៗទាក់ទងការប្រើ ក្រូមប៊ូគស៍ និង ការបន្តខ្សែបណ្តាញ គឺសូមទាក់ទងសាលារៀននៃសិស្សរបស់អ្នក ។

នៅក្នុងប្រព័ន្ធ Canvas គឺមានការតាំងបង្ហាញអំពីបណ្តាញសម្រាប់ Zoom ដែលកូនរបស់អ្នកអាចបើកប្រើបានសម្រាប់ទទួលការបង្ហាត់មេរៀនអោយឃើញភ្លាមៗ ។ សម្រាប់ការប្រើជំនួស ក្រែងលោសិស្សរបស់អ្នកមិនអាចបើកប្រើ Canvas បានភ្លាមៗ គឺសូមមេត្តាបើកមើលនៅតាមគេហទំព័រនៃសាលារៀនសម្រាប់សិស្សរបស់អ្នក និង ស្វែងរកបណ្តាញ Zoom ដែលមានភាពទាក់ទងគ្រូបង្រៀននៃសិស្សរបស់អ្នក ។

បើសិនជាអ្នកនៅតែត្រូវការចង់ដឹងបន្ថែមអំពីពេលវេលារៀនសម្រាប់សិស្សរបស់អ្នក និង ឈ្មោះអំពីគ្រូបង្រៀននៃសិស្សរបស់អ្នក សូមបើកមើលនៅក្នុង ParentVue ។ ចំពោះមាតាបិតា ដែលចង់បានពត៍មានបន្ថែមអំពី ParentVue គឺពួកគាត់អាចបើកចូលទៅ PARENTS > ParentVue Support នៅតាម lbschools.net ឬ ធ្វើការទាក់ទងផ្ទាល់ទៅកាន់សាលារៀននៃសិស្សរបស់ពួកគាត់ ។